ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ២៣.០១៣...០២៣...០៣៨ ប្រកាសព័ត៌មាន

ថ្ងៃពុធ ៦រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការចុះអនុស្សរណៈយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការទ្វេភាគី" រវាងធនាគារជាតិនៃកម្ពុជា និងសាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើនៃប្រទេសកូរ៉េ (KDIC)

នាថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈ-យោគយល់ (MoU) ស្តីពី "កិច្ចសហប្រតិបត្តិការទ្វេភាគី" ជាមួយសាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើនៃប្រទេសកូរ៉េ (KDIC) នៅទីក្រុងសេអ៊ូល សាធារណៈរដ្ឋកូរ៉េ។ ឯកឧត្តម គីមទី កោមលី អគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយ លោក ChaYong YOON អនុប្រធាននាយកប្រតិបត្តិសាជីវកម្ម KDIC។

ក្រោមអនុស្សរណៈយោគយល់នេះ ភាគីទាំងពីរនឹងចែករំលែកព័ត៌មាន ចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងការការពារប្រាក់បញ្ញើ និងដំណោះស្រាយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ គួររំលេចថា ធនាគារជាតិនៃកម្ពុជា និងសាជីវកម្ម KDIC ធ្លាប់បានចុះអនុស្សរណៈយោគយល់នេះម្តងរួចហើយ កាលពីឆ្នាំ២០១៧ ដែលមានសុពលភាព៣ឆ្នាំ និងបានផុតសុពលភាពក្នុងឆ្នាំ២០២០ កន្លងមកនេះ។ ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់ថ្មីនេះ នឹងអនុញ្ញាតឱ្យភាគីទាំងពីរបន្តរឹតចំណងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដើម្បីលើកកម្ពស់ការអភិវឌ្ឍសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ ជាពិសេសពាក់ព័ន្ធនឹងការការពារប្រាក់បញ្ញើ និងស្ថិរភាពហិរញ្ញវត្ថុ សម្រាប់ជាផលប្រយោជន៍រួមដល់ប្រទេសទាំងពីរ។ 

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA
https://www.tiktok.com/@nationalbankofcambodia_?_t=8fEbs8KK6Dg&_r=1